# អែលឌើរគ្រីស្ទហ្វឺសិនទៅទស្សនកិច្ចប្រទេសហ្វីលីពីន

ពួកសាវកធ្វើដំណើរជុំវិញពិភពលោក ដើម្បីផ្ដល់ការងារបម្រើដល់មនុស្ស ហើយបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។



អែលឌើរ ឌី ថត គ្រីស្ទហ្វឺសិន និងស៊ីស្ទើរ ខាធី គ្រីស្ទហ្វឺសិន បានទៅសួរសុខទុក្ខសមាជិកសាសនាចក្រនៅក្នុងប្រទេសហ្វីលីពីន ។ ប្រទេសនេះមានកោះជាង ៧០០០ កោះ ។ ហើយវាមានសមាជិកសាសនាចក្រជាង ៧៧០០០០ នាក់ ។



អែលឌើរគ្រីស្ទហ្វឺសិនបានមានប្រសាសន៍ថា ប្រសិនបើអ្នកទៅទស្សនកិច្ចប្រទេសហ្វីលីពីន នោះអ្នកនឹងមកផ្ទះវិញដោយស្នាមញញឹមនៅលើមុខរបស់អ្នក !



មានសមាជិកសាសនាចក្រជាច្រើននាក់មកពីប្រទេសហ្វីលីពីន—ជាពិសេសយុវនារី—បម្រើបេសកកម្ម ។ អែលឌើរគ្រីស្ទហ្វឺសិនបានមានប្រសាសន៍ថា គេស្គាល់ពួកគេថា ជាអ្នកពូកែរៀនភាសា ។

« វាគឺជាកិច្ចការតូចតាចដែលធ្វើឲ្យមានការផ្លាស់ប្ដូរយ៉ាងធំនៅក្នុងជីវិតនៃបុគ្គលម្នាក់។ និងគ្រួសារ » ។



**អែលឌើរគ្រីស្ទហ្វឺសិនបានបង្រៀនថា ៖**

ចូរមានសន្ដានចិត្តល្អ ហើយស្រឡាញ់គ្នាទៅវិញទៅមក ។ ការណ៍នេះហៅថាការងារបម្រើ ។

ចូររស់នៅតាមដំណឹងល្អ—គ្រប់បទបញ្ញត្តិទាំងអស់ !

ចែកចាយដំណឹងល្អជាមួយមនុស្សដទៃ ។

រូបថត © INTELLECTUAL RESERVE, INC.